ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៩-០៥-០០១ ស.ជ.ណ

# សារាចរណែនាំ

## ស្តីពីការធ្វើអាជីវកម្ម ទិញ-លក់ គ្រឿងអលង្ការ ត្បូងថ្ម និងលោហធាតុមានតំលៃ

ក្នុងគោលដៅលើកកំពស់ការទទួលខុសត្រូវរបស់ម្ចាស់អាជីវកម្មលក់ដូរគ្រឿងអលង្ការ ត្បូងថ្ម និងលោហធាតុមានតំលៃគ្រប់ប្រភេទ និងការពារផលប្រយោជន៍អតិថិជនជាតិ និងអតិថិជនជាភ្ញៀវបរទេស ក៏ដូចជាសំដៅលើកស្ទួយនិងរក្សាកិត្តិយសរបស់ជាតិ ធនាគារជាតិនៃកម្ពុជាសូមជូនដំណឹងនិងណែនាំដល់ម្ចាស់អាជីវកម្មលក់ដូរគ្រឿងអលង្ការ ត្បូងថ្ម និងលោហធាតុមានតំលៃ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តដូចខាងក្រោម៖

- ដោយអនុលោមតាមមាត្រា ៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ការប្រកបអាជីវកម្មលក់ដូរគ្រឿងអលង្ការ ត្បូងថ្ម និងលោហធាតុមានតំលៃ ត្រូវតែមានលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ។ ម្ចាស់អាជីវកម្មដែលបានទទួលការអនុញ្ញាតត្រូវប្រើប្រាស់លិខិតអនុញ្ញាតអាជីវកម្មអោយបានត្រឹមត្រូវ ដោយត្រូវគោរពអនុវត្តតាមការណែនាំ និងបទបញ្ជារបស់ធនាគារជាតិនៃកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយរបស់រដ្ឋ ។
- ម្ចាស់អាជីវកម្មត្រូវទទួលខុសត្រូវចំពោះការលក់ដូររបស់ខ្លួន ដោយមិនត្រូវធ្វើសកម្មភាពណា ឬលក់ដូរវត្ថុណាដែលមានលក្ខណៈភូតកុហក ពង្វាងការពិត ក្លែងបន្លំ ឬធ្វើអោយមានការភ័ន្តច្រឡំអំពីគុណភាពផលិតផលឡើយ ។
- ក្នុងដំណើការអាជីវកម្ម ម្ចាស់អាជីវកម្មលក់ដូរគ្រឿងអលង្ការ ត្បូងថ្ម និងលោហធាតុមានតំលៃ ត្រូវមានការទទួលខុសត្រូវ និងធានាលើផលិតផលរបស់ខ្លួន ទាំងបរិមាណ ទាំងគុណភាព និងតំលៃ ហើយត្រូវចេញវិក័យប័ត្រលក់ផលិតផល ព្រមទាំងមានលិខិតបញ្ជាក់ធានាគុណភាពលើផលិតផលរបស់ខ្លួនជូនអតិថិជនអោយបានត្រឹមត្រូវ ច្បាស់លាស់ ។

- ជនណាធ្វើអាជីវកម្ម ទិញ-លក់ គ្រឿងអលង្ការ ត្បូងថ្ម និងលោហធាតុមានតំលៃ ដោយគ្មានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា នឹងត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា ៧០ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។
- ម្ចាស់អាជីវកម្មលក់ដូរគ្រឿងអលង្ការ ត្បូងថ្ម និងលោហធាតុមានតំលៃ ដែលបានក្លែងបន្លំ ភូតភរ រំលោភលើសេចក្តីទុកចិត្ត និងឆបោកអតិថិជនជាអ្នកទិញ នឹងត្រូវដកហូតលិខិតអនុញ្ញាតអាជីវកម្ម ហើយត្រូវផ្តន្ទាទោសតាមបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌជាធរមាន ។

ធនាគារជាតិនៃកម្ពុជាសហការជាមួយ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ នឹងដំណើរការត្រួតពិនិត្យទីតាំងមូលដ្ឋានអាជីវកម្ម ដើម្បីបង្ការនិងទប់ស្កាត់ការលក់ដូរគ្រឿងអលង្ការក្លែងក្លាយ ដោយអនុវត្តតាមច្បាប់រដ្ឋជាធរមាន ។

ភ្នំពេញ ថ្ងៃទី០៩ ខែ មករា ឆ្នាំ ២០០៨

ទេសាភិបាល

ជា-ចាន់តូ

<u>ចម្លងជូន:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"
- ក្រសួងមហាផ្ទៃ
- សាលាក្រុងភ្នំពេញ "អភិបាលរាជធានីភ្នំពេញ"
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់សាខាធនាគារជាតិនៃកម្ពុជា ខេត្ត-ក្រុង
- កាលប្បវត្តិ
- ឯកសារ